# ព្រះរាជក្រម

នស/រកម/១១០៥/០៣៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃពិធីសារស្តីពីការប្រឆាំងការរត់ពន្ធជនអន្តោប្រវេសន៍នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាសដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារ ស្តីពីការប្រឆាំងការរត់ពន្ធជនអន្តោប្រវេសន៍ នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាស ដែលបំពេញបន្ថែមលើអនុសញ្ញា របស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្ម ឆ្លងដែនដែលមានអង្គការចាត់តាំង

មាត្រា ១.-

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារស្តីពីការប្រឆាំងការរត់ពន្ធជនអន្តោប្រវេសន៍នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាស ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងសម័យប្រជុំលើកទី ៥៥ តាមសេចក្តីសម្រេចលេខ ៥៥/២៥ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ នៅទីក្រុងញូវយ៉ក ហើយដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាចូលជាភាគី នាថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

[illegible]

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

សមាជិករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា ព្រះហស្តលេខា

ស ខេង នរោត្តម សិរីវុឌ្ឍ

លេខ [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

# ពិធីសារប្រឆាំងនៅនឹងការរត់ពន្ធជនអន្តោប្រវេសន៍ នៅតាមដែនគោក ដែនសមុទ្រ ដែនអាកាស និង ការបំពេញបន្ថែមនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែន

អត្ថបទដែលដកស្រង់ពីច្បាប់ដើម ការថតចម្លងនេះត្រូវ
បានបញ្ជាក់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ
និងត្រូវបានគេចេញផ្សាយនៅពេលក្រោយ

អង្គការសហប្រជាជាតិ
២០០០

# ពិធីសារប្រឆាំងទៅនឹងការរត់ពន្ធជនអន្តោប្រវេសន៍ នៅតាមដែនគោក ដែនសមុទ្រ ដែនអាកាស និង ការបំពេញបន្ថែមនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែន

## អារម្ភកថា

## ការចូលរួមរបស់បណ្តារដ្ឋដែលជាសមាជិកចំពោះពិធីសារនេះ

សេចក្តីប្រកាសស្តីអំពីសកម្មភាពដ៏មានប្រសិទ្ធភាពក្នុងកិច្ចការពារប្រឆាំងទៅនឹងការរត់ពន្ធជនអន្តោប្រវេសន៍ នៅតាមដែនគោក ដែនសមុទ្រ និងដែនអាកាសតម្រូវអោយមានការចូលរួមយ៉ាងទូលំទូលាយជាអន្តរជាតិ រួមមានទាំងកិច្ចសហប្រតិបត្តិការ ការផ្លាស់ប្តូរពត៌មានទៅវិញទៅមកហើយនិងវិធានការសមស្របដទៃទៀត ក្នុងនោះរួមមានវិធានការសេដ្ឋកិច្ច សង្គម ក្នុងកម្រិតជាតិ និងអន្តរជាតិនៅតាមតំបន់ ។

ការរំលឹកឡើងវិញនូវមហាសន្និបាត អង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៥៤/១២១២ នាថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ១៩៩៩ ក្នុងមហាសន្និបាតនេះបានជម្រុញអោយបណ្តារដ្ឋដែលជាសមាជិក និងអង្គការសហប្រជាជាតិពង្រឹងនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ នៅតាមតំបន់នូវផ្នែកអន្តោប្រវេសន៍អន្តរជាតិ ហើយនិងការអភិវឌ្ឍន៍ដើម្បីកត់សំគាល់នូវឬសគល់នៃបុព្វហេតុជនអន្តោប្រវេសន៍ ជាពិសេសបណ្តារដ្ឋជាសមាជិកទាំងនោះដែលទាក់ទិនទៅនឹងភាពក្រីក្រ ហើយនិងដើម្បីបង្កើននូវអត្ថប្រយោជន៍ដែលពាក់ព័ន្ធទៅនឹងជនអន្តោប្រវេសន៍អន្តរជាតិ និងធ្វើការលើកទឹកចិត្តកន្លែងណាដែលពាក់ព័ន្ធទៅនឹងយន្តការនៅតាមតំបន់ និងអនុតំបន់អន្តរជាតិ ដើម្បីបន្តដោះស្រាយនូវបញ្ហាអន្តោ-ប្រវេសន៍ និងការអភិវឌ្ឍន៍ ។

ធ្វើអោយជាក់លាក់នូវសេចក្តីត្រូវការដើម្បីផ្តល់អោយជនអន្តោប្រវេសន៍ ជាមួយនឹងការថែទាំដោយក្តីមេត្តា ហើយនិងកិច្ចការពារដ៏ពេញលេញនៃសិទ្ធិរបស់គេ ។

ទទួលខុសត្រូវនូវការពិត ថ្វីត្បិតតែកិច្ចការដែលបានធានាអះអាងនៅកិច្ចប្រជុំអន្តរជាតិដទៃទៀតក៏ដោយ ក៏មិនមានការអនុវត្តន៍ជាទូទៅដែលកត់សំគាល់នៅរាល់ចំណុចនៃការរត់ពន្ធជនអន្តោប្រវេសន៍ ហើយនិងបញ្ហាដែលទាក់ទិនដទៃទៀត ។

ទាក់ទិនទៅនឹងការកើនឡើងនូវសកម្មភាពសំខាន់ៗនៃក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងឡើងក្នុងការរត់ពន្ធជនអន្តោប្រវេសន៍ ហើយនិងទាក់ទិនទៅនឹងសកម្មភាពបទឧក្រិដ្ឋកម្មដទៃទៀត ដែលបានកំណត់ក្នុងពិធីសារនេះដែលនឹងនាំមកនូវផលអាក្រក់យ៉ាងធំដល់បណ្តារដ្ឋដែលពាក់ព័ន្ធ ។

ទន្ទឹមនឹងនោះការរត់ពន្ធជនអន្តោប្រវេសន៍ក៏មានពាក់ព័ន្ធផងដែរដែលអាចធ្វើអោយមានគ្រោះថ្នាក់ដល់អាយុជីវិត ឬក៏សុវត្ថិភាពដែលពាក់ព័ន្ធទៅនឹងជនអន្តោប្រវេសន៍ ។

ការរលឹកឡើងវិញនូវសេចក្តីសំរេចចិត្តរបស់អង្គការសហប្រជាជាតិលេខ ៥៣/១១១ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៨ តាមមហាសន្និបាតបានសំរេច ដើម្បីបង្កើតឡើងនូវគណៈកម្មាធិការសិទ្ធិមនុស្សមួយជាអន្តររដ្ឋាភិបាល ដោយគ្មានដែនកំណត់ក្នុងគោលបំណងពិភាក្សាអោយបានល្អិតល្អន់ទូលំទូលាយ នៃអនុសញ្ញាអន្តរជាតិក្នុងការប្រឆាំងនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ហើយនឹងធ្វើការពិភាក្សាគ្នាអោយបានហ្មត់ចត់ ក្នុងនោះរួមមានទាំងឯកសារច្បាប់អន្តរជាតិដែលបង្ហាញនូវការជួញដូរខុសច្បាប់ ក្នុងការដឹកជញ្ជូនជនអន្តោប្រវេសន៍នៅតាមដែនសមុទ្រ ។

ធ្វើអោយជាក់លាក់នូវការបំពេញបន្ថែមនៃអនុសញ្ញារបស់អង្គការសហប្រជាជាតិ ប្រឆាំងទៅនឹងបទឧក្រិដ្ឋ-កម្មឆ្លងដែនដែលមានអង្គការចាត់តាំង ជាមួយនឹងឯកសារច្បាប់អន្តរជាតិ ប្រឆាំងទៅនឹងការរត់ពន្ធជនអន្តោប្រវេស្តន៍តាមដែនគោក ដែនសមុទ្រ និងដែនអាកាស នឹងមានអត្ថប្រយោជន៍ក្នុងកិច្ចការពារ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មទាំងនោះ ។

បានការព្រមព្រៀងដូចខាងក្រោមនេះ:

## I-បទបញ្ញត្តិទូទៅ

### មាត្រា ១

### ការទាក់ទិនទៅនឹងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ប្រឆាំងនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង

១-ការបំពេញបន្ថែមនូវអនុសញ្ញារបស់អង្គការសហប្រជាជាតិ នៃពិធីសារនេះដើម្បីប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែន នឹងត្រូវបានបកស្រាយរួមគ្នាទៅតាមអនុសញ្ញា ។

២-បទបញ្ញត្តិនៃអនុសញ្ញានេះ នឹងអនុវត្តទៅតាមការផ្លាស់ប្តូរសមរម្យចំពោះពិធីសារនេះលុះត្រាតែមានអ្វីៗផ្សេងទៀតដែលមានចែងនៅទីនេះ ។

៣-បទល្មើសទាំងនេះបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រា ៦ នៃពិធីសារនេះនឹងត្រូវបានចាត់ទុកជាបទល្មើសដែលបានបង្កើតឡើងដោយយោងទៅតាមអនុសញ្ញា ។

### មាត្រា ២

### អត្ថប្រយោជន៍ នៃសេចក្តីថ្លែងការណ៍

គោលបំណងនៃពិធីសារនេះ ត្រូវតែការពារ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងអំពើរត់ពន្ធជនអន្តោប្រវេសន៍ ក៏ដូចជាការជំរុញអោយកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមរដ្ឋជាសមាជិកដែលបានបញ្ចប់ ក្នុងខណៈនៃកិច្ចការពារសិទ្ធិជនអន្តោប្រវេសន៍ដែលត្រូវបានរត់ពន្ធ ។

### មាត្រា ៣

### ការប្រើប្រាស់ពាក្យសំព្ទ

ចំពោះគោលបំណងនៃពិធីសារនេះគឺ :

(a)-"អំពើរត់ពន្ធជនអន្តោប្រវេសន៍" នឹងសំដែងអោយឃើញនូវការទាក់ទាញ ក្នុងគោលបំណងដើម្បីទទួលបាននូវផលប្រយោជន៍ផ្នែកសំភារៈ និងហិរញ្ញវត្ថុដោយផ្ទាល់ ឬដោយប្រយោលនៃជនណាម្នាក់ដែលបានចូលដោយខុសច្បាប់ទៅក្នុងរដ្ឋមួយជាសមាជិក ដែលជននោះមិនមែនជាសញ្ជាតិរបស់ខ្លួន ឬក៏ការគ្មានអាសយដ្ឋានអចិន្ត្រៃយ៍ ។

(b)-"ការចូលដោយខុសច្បាប់" មានន័យថាការឆ្លងកាត់ព្រំដែនដោយពុំបានអនុវត្តទៅតាមតម្រូវការជាចាំបាច់ ចំពោះការចូលដោយស្របច្បាប់ទៅក្នុងរដ្ឋដែលជាម្ចាស់ផ្ទះ ។

(c)-"ការបន្លំអត្តសញ្ញាណ ឬក៏ឯកសារធ្វើដំណើរ" គឺសំដៅទៅលើអត្តសញ្ញាណ ឬក៏ឯកសារនៃការធ្វើដំណើរណាមួយ ។

(i)-កិច្ចការដែលត្រូវបានធ្វើដោយក្លែងបន្លំ ឬក៏កែប្រែទៅតាមមធ្យោបាយសំភារៈខ្លះៗដោយជនណាម្នាក់ផ្សេងទៀត ឬក៏ទីភ្នាក់ងារណាមួយដែលត្រូវបានអនុញ្ញាតនូវច្បាប់ពេញលេញដើម្បីធ្វើ ឬក៏ចេញនូវឯកសារធ្វើដំណើរ ឬអត្តសញ្ញាណក្នុងនាមរដ្ឋមួយ ឬក៏

(ii)-កិច្ចការដែលត្រូវបានចេញផ្សាយមិនប្រក្រតី ឬក៏បានទទួលតាមរយៈការរាយការណ៍បំផ្លើស អំពើពុក-រលួយ ឬក៏ការបង្ខិតបង្ខំ ឬក៏ក្នុងលក្ខណៈខុសច្បាប់ដទៃផ្សេងទៀត ឬក៏

(iii)-កិច្ចការដែលកំពុងតែត្រូវបានប្រើប្រាស់ដោយបុគ្គលម្នាក់ដែលមិនមែនជាអ្នកកាន់កាប់ត្រឹមត្រូវ ។

(d)-"នាវា" គឺសំដៅទៅលើប្រភេទនាវាទឹកណាមួយដោយរាប់បញ្ចូលទាំងនាវាដែលទៅនឹងកន្លែង ហើយនឹងនាវាសមុទ្រដែលបានប្រើប្រាស់ ឬដែលអាចត្រូវបានប្រើប្រាស់ជាមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹកលើកលែងតែនាវាចំបាំង នាវាជំនួយ ឬក៏នាវាជាកម្មសិទ្ធិដទៃទៀតដែលប្រើប្រាស់ដោយរដ្ឋាភិបាលមួយ ហើយនឹងបានប្រើប្រាស់នាពេលបច្ចុប្បន្ននេះដោយរដ្ឋាភិបាលដែលមិនមែនជាសេវាកម្មខាងផ្នែកពាណិជ្ជកម្ម ។

## មាត្រា ៤
## វិសាលភាពនៃការអនុវត្តន៍

ពិធិសារនេះនឹងអនុវត្តលើកលែងតែពិធីសារផ្សេងទៀតដែលបានចែងនៅក្នុងមាត្រានេះដើម្បីធ្វើការទប់ស្កាត់ ធ្វើការស៊ើបអង្កេត ហើយនិងធ្វើការកាត់ទោសនៃបទល្មើសទាំងឡាយដែលបានបង្កើតឡើងដោយអនុលោមទៅតាម មាត្រា ៦ នៃពិធីសារនេះ ដែលបទល្មើសឆ្លងដែនទាំងនេះតាមធម្មតាពាក់ព័ន្ធទៅនឹងក្រុមឧក្រិដ្ឋជនមួយដែលបាន រៀបចំឡើង ព្រមទាំងពាក់ព័ន្ធទៅនឹងកិច្ចការពារសិទ្ធិមនុស្សនៃអ្នកទាំងឡាយដែលមានទោសកម្មផ្នែកបទល្មើសដូច នេះ ។

## មាត្រា ៥
## ការទទួលខុសត្រូវនៃបទឧក្រិដ្ឋផ្នែកជនអន្តោប្រវេសន៍

ជនអន្តោប្រវេសន៍ទាំងអស់នឹងមិនអាចទទួលយកបាននូវការកាត់ទោសផ្នែកបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោម ពិធីសារនេះ ចំពោះភាពពិតដែលបានប្រព្រឹត្តនូវទោសកម្មចំពោះមុខដូចបានកំណត់ក្នុងមាត្រា ៦ នៃពិធីសារនេះ ។

## មាត្រា៦
## ការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម

១-រដ្ឋនិមួយៗដែលជាសមាជិកគួរតែអនុម័តនូវនីតិបញ្ញត្តិ ហើយនឹងវិធានការផ្សេងទៀតដែលចាំបាច់ដើម្បី បង្កើតឡើងនូវបទល្មើសឧក្រិដ្ឋនៅពេលដែលជនទាំងឡាយណាដែលបានប្រព្រឹត្តដោយចេតនា ហើយនិងទទួលយកនូវ ផលប្រយោជន៍ផ្នែកសម្ភារៈ ឬក៏ផ្នែកហិរញ្ញវត្ថុដទៃទៀតដោយផ្ទាល់ ឬដោយប្រយោល ។

(a)-ការជួញដូរជនអន្តោប្រវេសន៍

(b)-ការប្រព្រឹត្តនោះក្នុងគោលបំណងរត់ពន្ធជនអន្តោប្រវេសន៍

(i)-ការបន្លំឯកសារធ្វើដំណើរ ឬអត្តសញ្ញាណ

(ii)-ការផ្គត់ផ្គង់ ការផ្តល់អោយនូវឯកសារ ឬក៏ជាឯកសារផ្ទាល់ខ្លួន

(c)-ចំពោះជនណាដែលមិនមានសញ្ជាតិ ឬក៏នៅតែបន្តការស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋដែល ពាក់ព័ន្ធដោយមិនអនុវត្តតាមនូវសេចក្តីតម្រូវការជាចាំបាច់ចំពោះច្បាប់ជាធរមាននៅក្នុងរដ្ឋនោះ តាមអត្ថន័យដែលបានពោល ខាងលើនៅក្នុងវាក្យខ័ណ្ឌ (b) នៃកឋាខ័ណ្ឌនេះ ឬក៏វិធីខុសច្បាប់ ដទៃផ្សេងទៀត ។

២-រដ្ឋនីមួយៗដែលជាសមាជិកគួរតែអនុម័តនូវច្បាប់ ហើយនឹងវិធានការដទៃផ្សេងទៀតផងដែរដែលចាំបាច់ ដើម្បីបង្កើតឡើងនូវបទល្មើសផ្នែកឧក្រិដ្ឋ ។

(a)-ប្រធានបទចំពោះទស្សនៈជាមូលដ្ឋាននៃប្រព័ន្ធច្បាប់របស់វា មានគោលបំណងប្រព្រឹត្តនូវបទ ល្មើសដែលបានបង្កើតឡើង ដោយអនុលោមទៅតាមវាក្យខ័ណ្ឌ ១ នៃមាត្រានេះ ។

(b)-ការចូលរួមផ្សំគំនិតនៅក្នុងបទល្មើសណាមួយ ដែលបានបង្កើតឡើងដោយអនុលោមទៅតាម កឋាខ័ណ្ឌ ១ (a), (b)(i) ឬក៏ (c) នៃមាត្រានេះ ហើយក៏ជាប្រធានបទចំពោះទស្សនៈជាមូលដ្ឋាន នៃប្រព័ន្ធច្បាប់របស់ខ្លួនការចូលរួមផ្សំគំនិតនៅក្នុងបទល្មើសណាមួយដែលបានបង្កើតឡើងដោយ អនុលោម ទៅតាមកឋាខ័ណ្ឌ ១ (b) (ii) នៃមាត្រានេះ ។

(c)-ការចាត់តាំង ឬក៏ការរៀបចំនូវបណ្តាជនដទៃទៀត ដើម្បីប្រព្រឹត្តនូវបទល្មើសដែលបានបង្កើត ឡើងដោយអនុលោមទៅតាមកឋាខ័ណ្ឌ ១ នៃមាត្រានេះ ។

៣-រដ្ឋនីមួយៗដែលជាសមាជិកត្រូវតែអនុម័តទៅតាមការតាក់តែងច្បាប់នេះ ហើយនិងវិធានការដទៃទៀត ដែលចាំបាច់ ដើម្បីបង្កើតឡើងតាមកាលៈទេសៈដ៏ស្មុគស្មាញ ចំពោះបណ្តាបទល្មើសដែលបានបង្កើតឡើងដោយអនុលោមទៅតាមកថាខ័ណ្ឌ ២ (b) និង (c) នៃមាត្រានេះដោយយោងទៅតាមកាលៈទេសៈ ។

(a)-ការដែលធ្វើអោយមានគ្រោះថ្នាក់ ឬក៏ដូចជាធ្វើអោយមានគ្រោះថ្នាក់ដល់អាយុជីវិត ឬក៏ផ្នែកសុវត្ថិភាពដែលពាក់ព័ន្ធទៅនឹងផ្នែកជនអន្តោប្រវេសន៍ ។

(b)-ការដែលធ្វើអោយមានភាពអមនុស្សធម៌ ឬក៏ការមិនយកចិត្តទុកដាក់ផ្នែកសេវាសុខភាពព្រមទាំងមានការកេងប្រវ័ញ្ចចំពោះជនអន្តោប្រវេសន៍ ។

៤-នៅក្នុងពិធីសារនេះគ្មាន អ្វីដែលរារាំងចំពោះរដ្ឋមួយដែលចាត់នូវរាល់វិធានការប្រឆាំងទៅនឹងបុគ្គលណាមួយដែលជាអ្នកប្រព្រឹត្តនូវបទល្មើសមួយដែលផ្ទុយទៅនឹងច្បាប់ប្រទេសរបស់ខ្លួន ។

## II-ការរត់ពន្ធផ្នែកជនអន្តោប្រវេសន៍នៅតាមដែនសមុទ្រ

### មាត្រា ៧

### កិច្ចសហប្រតិបត្តិការ

បណ្តារដ្ឋដែលជាសមាជិកទាំងអស់ នឹងធ្វើកិច្ចសហប្រតិបត្តិការដើម្បីបំពេញនូវវិសាលភាពដែលអាចធ្វើទៅបានក្នុងកិច្ចការពារ និងទប់ស្កាត់រាល់អំពើរត់ពន្ធជនអន្តោប្រវេសន៍នៅតាមដែនសមុទ្រ ដោយយោងទៅតាមច្បាប់ដែនសមុទ្រអន្តរជាតិ ។

### មាត្រា ៨

### បណ្តាវិធានការប្រឆាំងទៅនឹងអំពើរត់ពន្ធជនអន្តោប្រវេសន៍នៅតាមដែនសមុទ្រ

១-រដ្ឋមួយដែលជាសមាជិកមានហេតុផលក្នុងពីបទសង្ស័យថានាវាមួយនោះកំពុងតែដោយទង់ជាតិរបស់ខ្លួន ឬក៏ អះអាងថាបានចុះឈ្មោះក្នុងបញ្ជីរបស់ខ្លួនដោយពុំបានបញ្ជាក់ពីសញ្ជាតិពិតប្រាកដ ឬបើទោះបីជាការប្រើប្រាស់ទង់ជាតិ បរទេស ឬក៏បដិសេធមិនបង្ហាញទង់ជាតិ និងសញ្ជាតិពិតប្រាកដដែលពាក់ព័ន្ធទៅនឹងរដ្ឋជាសមាជិកដែលបានសន្យា ក្នុងការរត់ពន្ធជនអន្តោប្រវេសន៍តាមដែនសមុទ្រ អាចសំណូមពរអោយមានការជួយពីបណ្តារដ្ឋដែលជាសមាជិកផ្សេង ក្នុងការទប់ស្កាត់នូវគោលបំណងនៃការប្រើប្រាស់នាវានោះ ។ បណ្តារដ្ឋដែលជាសមាជិកក៏បានសំណូមពរផងដែរនឹងផ្តល់នូវការជួយឧបត្ថម្ភទៅតាមលទ្ធភាព និងមធ្យោបាយរបស់គេ ។

២-រដ្ឋមួយជាសមាជិកដែលមានហេតុផលពិតប្រាកដ ពីបទសង្ស័យទៅលើនាវាមួយដែលបើកបរដោយសេរីអនុលោមតាមច្បាប់អន្តរជាតិ ហើយប្រើប្រាស់ទង់ជាតិ ឬក៏បង្ហាញនូវសញ្ញាដែលចុះទៅក្នុងបញ្ជីនៃរដ្ឋដែលជាសមាជិកមួយផ្សេងទៀតដែលបានជាប់ពាក់ព័ន្ធការរត់ពន្ធជនអន្តោប្រវេសន៍តាមដែនសមុទ្រ អាចនឹងបង្ហាញនូវទង់ជាតិរបស់រដ្ឋនោះ ស្នើសុំអោយមានការអះអាងនៃការចុះបញ្ជី ប្រសិនបើមានការអះអាងរួចហើយធ្វើការស្នើសុំទៅអាជ្ញាធរពីទង់ជាតិនៃរដ្ឋនោះដើម្បីចាត់នូវវិធានការដ៏ត្រឹមត្រូវជាមួយនឹងនាវានោះ ។ ទង់ជាតិនៃរដ្ឋនោះអាចនឹងអនុញ្ញាតទៅតាមសំណូមពរនៃរដ្ឋមួយទៀត ។

(a)-ការជិះនៅលើនាវា

(b)-ការស្រាវជ្រាវនៅលើនាវា ហើយនឹង

(c)-ប្រសិនបើរកឃើញភស្តុតាងថានាវានោះត្រូវបានជាប់ពាក់ព័ន្ធ ក្នុងការរត់ពន្ធជនអន្តោប្រវេសន៍តាមដែនសមុទ្រត្រូវតែចាត់នូវរាល់វិធានការអោយបានសមស្រប ចំពោះនាវាដែលដឹកជញ្ជូនមនុស្ស និងទំនិញនៅលើនាវា នោះតាមការអនុញ្ញាតដោយទង់ជាតិនៃរដ្ឋនីមួយៗ ។

៣-រដ្ឋមួយដែលជាសមាជិកបានអនុវត្តទៅតាមវិធានការណាមួយ ដោយអនុលោមទៅតាមកថាខ័ណ្ឌ ២ នៃមាត្រានេះ នឹងជូនដំណឹងជាមុននូវទង់ជាតិរដ្ឋដែលពាក់ព័ន្ធនឹងលទ្ធផលនៃវិធានការទាំងអស់នោះ ។

៤-រដ្ឋមួយដែលជាសមាជិកនឹងឆ្លើយតបជាបន្ទាន់ ចំពោះសំណូមពរពីបណ្តារដ្ឋដែលជាសមាជិកមួយផ្សេងទៀតដើម្បីធ្វើការសំរេចចិត្តថាតើនាវានោះ ដែលបានធ្វើការអះអាងថាការចុះបញ្ជីឈ្មោះរបស់ខ្លួន ឬក៏ប្រើប្រាស់ទង់ជាតិរបស់ខ្លួនត្រូវបានផ្តល់សិទ្ធិអោយធ្វើដូច្នេះ ហើយនិងស្នើសុំសិទ្ធិអនុវត្តដោយអនុលោមទៅតាមវគ្គ ២ នៃមាត្រានេះ ។

៥-ទង់ជាតិនៃរដ្ឋមួយអាចនឹងស្របទៅតាមមាត្រា ៧ នៃពិធីសារនេះ ប្រធានបទនៃការផ្តល់សិទ្ធិអោយចំពោះលក្ខខ័ណ្ឌណាមួយដែលត្រូវបានយល់ព្រមដោយរដ្ឋ ហើយនិងរដ្ឋមួយទៀតដែលស្នើសុំដោយរាប់បញ្ចូលទាំងលក្ខខ័ណ្ឌដែលទាក់ទិនទៅនឹងការទទួលខុសត្រូវ ហើយនិងអនុវត្តវិធានការដ៏មានប្រសិទ្ធភាព ។ រដ្ឋមួយដែលជាសមាជិកនិង មិនត្រូវចាត់នូវរាល់វិធានការបន្ថែមដោយគ្មានការបង្ហាញនូវសេចក្តីអនុញ្ញាតនៃទង់ជាតិនៃរដ្ឋនោះ លើកលែងតែបញ្ហាទាំងនោះមិនអាចជៀសរួច ដើម្បីជួយសង្គ្រោះដល់អាយុជីវិតរបស់មនុស្សដែលមានគ្រោះថ្នាក់ភ្លាមៗ ឬក៏បញ្ហានោះបណ្តាលមកពីការ ពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងរវាងទ្វេភាគី ឬក៏ពហុភាគី ។

៦-រដ្ឋនីមួយៗដែលជាសមាជិកនឹងត្រូវកំណត់ទុកជាមុននូវអាជ្ញាធរដែលមានសមត្ថកិច្ច ឬក៏ក្នុងករណីចាំបាច់ណាមួយអ្នកមានសមត្ថកិច្ចទាំងនោះទទួល និងឆ្លើយតបទៅតាមការស្នើសុំជំនួយដោយធ្វើ ការបញ្ជាក់អះអាងនូវបញ្ជីឈ្មោះ ឬការផ្តល់សិទ្ធិអោយនាវានោះបង្ហាញទង់ជាតិរបស់ខ្លួន ហើយចំពោះការផ្តល់សិទ្ធិនោះត្រូវចាត់នូវវិធានការអោយបានសមស្រប ។ តាមការកំណត់ទុកជាមុននេះនឹងត្រូវបានជូនដំណឹងតាមរយៈអគ្គលេខាធិការរបស់បណ្តារដ្ឋដែលជាសមាជិកទាំងអស់ក្នុងរយៈពេលកំណត់មួយខែម្តង ។

៧-រដ្ឋមួយដែលជាសមាជិកមានមូលបទសមហេតុផលពីបទសង្ស័យថា នាវាមួយនោះត្រូវបានជាប់ពាក់ព័ន្ធក្នុងការរត់ពន្ធជនអន្តោប្រវេសន៍តាមដែនសមុទ្រហើយនិងមិនបានបញ្ជាក់នូវសញ្ជាតិ ឬក៏អាចនឹងប្រហាក់ប្រហែលទៅនឹងនាវាដែលមិនបានបញ្ជាក់ពីសញ្ជាតិអាចនឹងជិះ ហើយនិងស្រាវជ្រាវនៅលើនាវានោះ ។

ប្រសិនបើមានការបញ្ជាក់នូវភស្តុតាងពីបទសង្ស័យ ដែលត្រូវបានរកឃើញនោះ រដ្ឋមួយដែលជាសមាជិកនឹងត្រូវចាត់វិធានការអោយបានសមស្រប ដោយអនុលោមទៅតាមការពាក់ព័ន្ធទៅនឹងច្បាប់របស់ប្រទេសរបស់ខ្លួន និងច្បាប់អន្តរជាតិ ។

## មាត្រា ៩
## ផ្នែកនៃកិច្ចការពារ

១-រដ្ឋមួយដែលជាសមាជិក ដែលបានចាត់វិធានការប្រឆាំងនឹងនាវាមួយដោយអនុលោមទៅតាមមាត្រា ៨ នៃពិធីសារនេះនឹងត្រូវ:

(a)-ធានានូវសុវត្ថិភាព ហើយនិងយកចិត្តទុកដាក់ថែទាំដោយក្តីមនុស្សធម៌ដល់មនុស្សគ្រប់រូបដែលជិះនៅលើនាវានោះ ។

(b)-ទទួលខុសត្រូវនូវរាល់សេចក្តីត្រូវការ ដោយមិនបង្កអោយមានគ្រោះថ្នាក់ផ្នែកសន្តិសុខដល់នាវា ឬក៏នាវាដឹកជញ្ជូនទំនិញខ្លួន ។

(c)-ទទួលខុសត្រូវនូវរាល់សេចក្តីត្រូវការ មិនធ្វើអោយប៉ះពាល់ដល់ផ្នែកពាណិជ្ជកម្ម ឬក៏ចាប់អារម្មណ៍ទៅលើទង់ជាតិនៃរដ្ឋមួយដែលស្របច្បាប់ ឬក៏ចាប់អារម្មណ៍ទៅលើរដ្ឋដទៃផ្សេងទៀត ។

(d)-ធានានូវមធ្យោបាយដែលអាចធ្វើទៅបាននៃវិធានការណាមួយដែលនាវានោះធ្វើអោយឮសំលេងប៉ះពាល់ដល់បរិស្ថាន ។

២-ហេតុផលទាំងឡាយសំរាប់ចាត់វិធានការដោយអនុលោមទៅតាមមាត្រា ៨ ដែលបានបង្ហាញក្នុងពិធីសារនេះមិនត្រូវបានបង្កើតឡើង នាវានោះនឹងត្រូវបានសងថ្លៃជំងឺចិត្តចំពោះការបាត់បង់ ឬក៏ការខូចខាតណាមួយដែលអាច

នឹងត្រូវបានទទួលរ៉ាប់រង ហើយប្រគល់នូវការសងជំងឺចិត្តដល់នាវាណាដែលមិនបានប្រព្រឹត្តនូវអំពើណាមួយ ដោយបង្ហាញនូវហេតុផលត្រឹមត្រូវទៅតាមវិធានការដែលបានអនុវត្ត ។

៣-វិធានការណាមួយដែលបានរៀបចំឡើងបានអនុម័ត ឬក៏បានអនុវត្តដោយអនុលោមទៅតាមជំពូកនេះនឹងត្រូវទទួលខុសត្រូវនូវរាល់សេចក្តីត្រូវការណាដែលមិនបង្កនូវការជ្រៀតជ្រែក ឬក៏ប៉ះពាល់ដល់ :

(a)-សិទ្ធិ និងកាតព្វកិច្ចព្រមទាំងការអនុវត្តន៍នូវសិទ្ធិស្របច្បាប់នៅដែនសមុទ្ររបស់បណ្តារដ្ឋដោយអនុលោមទៅតាមច្បាប់ដែនសមុទ្រអន្តរជាតិ ឬក៏....

(b)-ការអនុញ្ញាតអោយប្រើប្រាស់ទង់ជាតិរបស់រដ្ឋ ដើម្បីអនុវត្តទៅតាមផ្លូវច្បាប់ ហើយនឹងត្រួត-ពិនិត្យទៅក្នុងផ្នែករដ្ឋបាល ផ្នែកបច្ចេកទេស និងបញ្ហាសង្គមដែលពាក់ព័ន្ធទៅនឹងនាវា ។

៤-ការចាត់នូវវិធានការណាមួយនៅតាមដែនសមុទ្រ ដោយអនុលោមទៅតាមជំពូកនេះនឹងត្រូវបានអនុវត្តចំពោះតែនាវាចំបាំង ឬក៏យន្តហោះចំបាំងរបស់យោធាតែប៉ុណ្ណោះ ឬក៏បណ្តានាវាដទៃផ្សេងទៀត និងយន្តហោះដទៃដែលបានធ្វើសញ្ញាច្បាស់លាស់ ព្រមទាំងអាចបញ្ជាក់ថាជាសេវាកម្មរបស់រដ្ឋាភិបាល ហើយនឹងបានអនុញ្ញាតអោយដោយមានប្រសិទ្ធិភាព ។

## III- កិច្ចការពារ កិច្ចសហប្រតិបត្តិការ ហើយនឹងបណ្តាវិធានការដទៃផ្សេងទៀត

### មាត្រា១០

### ពត៌មាន

១-គ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់មាត្រា ២៧ ហើយនិងមាត្រា ២៨ នៃអនុសញ្ញារបស់បណ្តារដ្ឋដែលជាសមាជិកនេះទេ ជាពិសេសបណ្តារដ្ឋទាំងនោះដែលមានទីតាំង ឬក៏ព្រំដែនរួមគ្នាដែលជាផ្លូវរត់ពន្ធជនអន្តោប្រវេសន៍ និងជាគោលបំណងនៃការសំរេចទិសដៅរបស់ពិធីសារនេះ ការផ្លាស់ប្តូរក្នុងចំណោមពួកគេស្របទៅតាមប្រព័ន្ធរដ្ឋបាល ហើយនិងច្បាប់ប្រទេសរៀងៗខ្លួនរបស់ពួកគេ ពត៌មានដែលពាក់ព័ន្ធទៅនឹងហេតុការណ៍ជាច្រើននោះមានដូចខាងក្រោមនេះ :

(a)-ចំណុចនៃការចុះនាវា ហើយនិងគោលដៅព្រមទាំងផ្លូវគ្រឿងដឹកឥវ៉ាន់និងមធ្យោបាយដឹកជញ្ជូនដែលត្រូវបានគេស្គាល់ថាឬក៏ត្រូវបានគេសង្ស័យថាបានប្រើប្រាស់ដោយក្រុមឧក្រិដ្ឋជនមួយដែលបានចាត់តាំងឡើងពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តដូចដែលបានកំណត់ទុកក្នុងមាត្រា ៦ នៃពិធីសារនេះ ។

(b)-ភារចាត់ចែងឡើងនូវរបៀបកម្មវិធី និងផ្នែកអត្តសញ្ញាណ ឬក៏បានរៀបចំឡើងនូវបណ្តាក្រុមឧក្រិដ្ឋជនដែលត្រូវបានគេស្គាល់ ឬក៏បានសង្ស័យថាបានជាប់ពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តដូចដែលមានចែង នៅក្នុងមាត្រា ៦ នៃពិធីសារនេះ ។

(c)-បែបបទនៃឯកសារធ្វើដំណើរមានភាពត្រឹមត្រូវទៅតាមច្បាប់ពិតប្រាកដ ដែលបានចេញអោយប្រើប្រាស់ដោយរដ្ឋមួយដែលជាសមាជិក ឬក៏ការពាក់ព័ន្ធទៅនឹងការធ្វើដំណើរដោយគ្មានភាពត្រឹមត្រូវ និងការលួចបន្លំឯកសារអត្តសញ្ញាណ ឬក៏ឯកសារធ្វើ ដំណើរមិនត្រឹមត្រូវ ។

(d)-ការលាក់បំបាំងនូវរាល់របៀបវិធី ហើយនិងរាល់មធ្យោបាយ និងការដឹកជញ្ជូនមនុស្សការបំផ្លែងភេទមិនត្រឹមត្រូវតាមលក្ខណៈច្បាប់ ការរៀបចំឡើងវិញ ឬក៏ការរកបានមក ឬក៏ការធ្វើដំណើរដោយមិនត្រឹមត្រូវដទៃទៀតដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តដូចដែលមានចែងនៅក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយនិង រាល់វិធីនៃការស៊ើបអង្កេតនូវបណ្តាហេតុការណ៍ទាំងឡាយ ។

(e)-បទពិសោធន៍នៃការតាក់តែងច្បាប់ ហើយនិងការអនុវត្តន៍នូវវិធានការដើម្បីការពារ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងការប្រព្រឹត្តដូចដែលមានចែងនៅក្នុងមាត្រា ៦ នៃពិធីសារនេះ ឬក៏....

(f)-ផ្ដែកពត៌មានវិទ្យា ហើយនិងផ្នែកវិទ្យាសាស្ត្រមានអត្ថប្រយោជន៍ចំពោះការអនុវត្តន៍ច្បាប់ក៏ដូច ជាការបង្កើនឡើងនូវសមត្ថភាពរវាងគ្នាទៅវិញទៅមកដើម្បីស្រាវជ្រាវ ព្រមទាំងស៊ើបអង្កេត នូវការប្រព្រឹត្តដូចដែលមានចែងនៅក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយនិងផ្ដន្ទាទោសចំពោះ អំពើដែលពាក់ព័ន្ធទាំងនោះ ។

២-រដ្ឋមួយដែលជាសមាជិកដែលទទួលបានពត៌មាននឹងត្រូវអនុវត្តទៅតាម សេចក្ដីស្នើសុំណាមួយដោយភាគី រដ្ឋមួយជាសមាជិកផ្សេងទៀតដែលបានបញ្ជូនពត៌មានតាមទីកន្លែងដាក់លាក់ស្ដីពីការប្រើប្រាស់របស់ខ្លួន ។

## មាត្រា ១១
## បណ្ដាវិធានការនៅតាមព្រំដែន

១-គ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់ការអនុវត្តន៍ជាលក្ខណៈអន្តរជាតិ ក្នុងទំនាក់ទំនងចំពោះចលនាសេរីភាព របស់ប្រជាជន បណ្ដារដ្ឋដែលជាសមាជិកត្រូវតែពង្រឹងអោយអស់ពីលទ្ធភាព ដូចជាការត្រួតពិនិត្យនៅតាមព្រំដែន ដែលចាំបាច់ដើម្បីការពារ ហើយនិងស៊ើបអង្កេតនូវការរត់ពន្ធជនអន្តោប្រវេសន៍ ។

២-រដ្ឋនីមួយៗដែលជាសមាជិកនឹងត្រូវអនុម័តច្បាប់ ឬក៏បណ្ដាវិធានការសមស្របដទៃទៀតដើម្បីការពារ អោយអស់លទ្ធភាពនូវរាល់មធ្យោបាយដឹកជញ្ជូន ដែលបានប្រព្រឹត្តដោយឈ្មួញពាណិជ្ជកម្ម ពីការប្រើប្រាស់ក្នុងការ ប្រព្រឹត្តនូវបទល្មើសដែលបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រា ៦ កថាខ័ណ្ឌ ១ (a) នៃពិធីសារនេះ ។

៣-អ្វីដែលជាភាពសមរម្យហើយនឹងគ្មានការប៉ះពាល់ដល់ការអនុវត្តន៍នៃអនុសញ្ញាអន្តរជាតិ ក៏ដូចជាបណ្ដា វិធានការទាំងឡាយដែលត្រូវចាប់បញ្ចូលនូវការបង្កើនឡើងកាតព្វកិច្ចនៃឈ្មួញពាណិជ្ជកម្ម រួមមាន ក្រុមហ៊ុនដឹកជញ្ជូន ណាមួយ ឬក៏ម្ចាស់ក្រុមហ៊ុន ឬក៏អ្នកប្រព្រឹត្តរាល់មធ្យោបាយដឹកជញ្ជូនណាមួយ ដើម្បីបញ្ជាក់អោយច្បាស់ថារាល់ អ្នកធ្វើដំណើរទាំងឡាយត្រូវតែតម្រូវអោយមានឯកសារធ្វើដំណើរផ្ទាល់ខ្លួនក្នុងការចូលទៅរដ្ឋដែលជាម្ចាស់ផ្ទះ ។

៤-រដ្ឋនីមួយៗដែលជាសមាជិកនឹងត្រូវចាត់នូវរាល់វិធានការជាចាំបាច់ ដោយអនុលោមតាមច្បាប់ក្នុងស្រុក របស់ខ្លួន និងផ្ដល់ការដាក់ទណ្ឌកម្មក្នុងករណីដែលរំលោភទៅលើកាតព្វកិច្ចដូចដែលមានចែងក្នុងកថាខ័ណ្ឌ ៣ នៃមា- ត្រានេះ ។

៥-រដ្ឋនីមួយៗដែលជាសមាជិកនឹងត្រូវពិចារណា ក្នុងការចាត់នូវរាល់វិធានការដែលបានអនុញ្ញាតដោយយោង ទៅតាមច្បាប់ប្រទេសរបស់ខ្លួន ការបដិសេធនៃការចូល ឬក៏មោឃភាពនៃទិដ្ឋាការនូវរាល់ជនទាំងឡាយណាដែល បានជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសដែលបានបង្កើតឡើងដោយអនុលោមទៅតាមពិធីសារនេះ ។

៦-គ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់មាត្រា ២៧ នៃអនុសញ្ញានេះទេ បណ្ដារដ្ឋដែលជាសមាជិកនឹងត្រូវ ពិចារណាពង្រឹងនូវកិច្ចសហប្រតិបត្តិការក្នុងចំណោមទីភ្នាក់ងារត្រួតពិនិត្យព្រំដែនរវាងគ្នាទៅវិញទៅមកក្នុងការបង្កើត ឡើង ហើយនិងការថែរក្សាដោយផ្ទាល់នូវប្រព័ន្ធទំនាក់ទំនង ។

## មាត្រា ១២
## សន្តិសុខ និងការគ្រប់គ្រងឯកសារ

រដ្ឋនីមួយៗដែលជាសមាជិក ត្រូវចាត់នូវរាល់វិធានការចាំបាច់ទៅតាមមធ្យោបាយដែលអាចយកជាការបាន ។

(a)-ដើម្បីធានានូវរាល់ឯកសារធ្វើដំណើរ ឬក៏អត្តសញ្ញាណនានាដែលត្រូវបានចេញអោយប្រើប្រាស់ ដោយខ្លួនឯងក្នុងលក្ខណៈដែលគេមិនអាចប្រើប្រាស់ផ្លូវខុសដោយងាយៗនោះទេ ហើយមិនត្រូវបានគេធ្វើ អោយខុស ឬត្រូវបានកែប្រែខុសច្បាប់ បានចម្លង ឬក៏បានចេញផ្សាយ និង

(b)-ដើម្បីធានាសេចក្ដីសុចរិត និងសន្តិសុខនៃឯកសារធ្វើដំណើរ ឬអត្តសញ្ញាណបានចេញអោយ ប្រើប្រាស់ ឬតាងនាមភាគីរដ្ឋជាសមាជិក ហើយដើម្បីទប់ស្កាត់ការបង្កើតឡើងដែលខុសច្បាប់របស់ខ្លួននូវ រាល់ការចេញផ្សាយ និងការប្រើប្រាស់ ។

## មាត្រា ១៣
## ធម្មនុញ្ញភាព និងសុពលភាពនៃឯកសារ

តាមសំណូមពរនៃរដ្ឋជាសមាជិកមួយដោយអនុលោមទៅតាមច្បាប់នៅក្នុងប្រទេសរបស់ខ្លួន រដ្ឋជាសមាជិកមួយត្រូវត្រួតពិនិត្យមើលធម្មនុញ្ញភាព និងសុពលភាពនៃឯកសារធ្វើដំណើរ ឬអត្តសញ្ញាណដែលបានចេញអោយការប្រើប្រាស់ ឬមានន័យអោយស្របតាមពេលវេលា ត្រូវបានផ្សព្វផ្សាយក្នុងនាមរបស់ខ្លួន ហើយដែលបានមន្ទិលនូវការដែលបានប្រើប្រាស់ចំពោះបណ្តាគោលបំណងនៃការប្រព្រឹត្តបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។

## មាត្រា ១៤
## ការបណ្តុះបណ្តាល និងកិច្ចប្រតិបត្តិការផ្នែកបច្ចេកទេស

១-ភាគីរដ្ឋជាសមាជិកទាំងអស់ត្រូវផ្តល់ ឬពង្រឹងការហ្វឹកហ្វឺនជំនាញចំពោះការធ្វើអន្តោប្រវេសន៍ និងមន្ត្រីដែលពាក់ព័ន្ធដទៃទៀតក្នុងការទប់ស្កាត់បទល្មើសបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយក្នុងការព្យាបាលមនុស្សជាជនអន្តោប្រវេសន៍ដែលបានជាកម្មវត្ថុនៃការប្រព្រឹត្តនេះ ខណៈដែលគេគោរពសិទ្ធិរបស់ពួកគេដូវមានចែងក្នុងពិធី-សារនេះ ។

២-រដ្ឋជាសមាជិកទាំងអស់ត្រូវប្រតិបត្តិការជាមួយគ្នា ហើយតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ចនានា អង្គការមិនមែនរដ្ឋាភិបាល អង្គការដែលពាក់ព័ន្ធដទៃទៀត និងអង្គការសង្គមស៊ីវិលផ្សេងទៀត ដើម្បីធានាការហ្វឹកហ្វឺនបុគ្គលិកគ្រប់គ្រាន់ក្នុងបូរណភាពទឹកដីរបស់ខ្លួន ដើម្បីទប់ស្កាត់ប្រយុទ្ធប្រឆាំង និងលុបបំបាត់ចោលការប្រព្រឹត្តដែលបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយដើម្បីការពារសិទ្ធជនអន្តោប្រវេសន៍ដែលបានប្រព្រឹត្តនូវទោសកម្មនេះ ។ ការហ្វឹកហ្វឺននេះត្រូវដាក់បញ្ចូល :

(a)-បង្កើនសន្តិសុខ និងគុណភាពឯកសារធ្វើដំណើរ

(b)-ទទួលស្គាល់ និងស៊ើបអង្កេតឯកសារធ្វើដំណើរ ឬក៏អត្តសញ្ញាណដែលក្លែងបន្លំ

(c)-ប្រមូលផ្តុំការស៊ើបអង្កេតបទល្មើសជាពិសេសទាក់ទិនទៅនឹងអត្តសញ្ញាណនៃក្រុមឧក្រិដ្ឋជនដែលគេស្គាល់ ឬបានសង្ស័យពីការចូលរួមក្នុងការប្រព្រឹត្តបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។ បណ្តាមធ្យោបាយដែលបានប្រើប្រាស់ដើម្បីដឹកជញ្ជូនជនអន្តោប្រវេសន៍ដែលត្រូវបានគេជួញដូរការប្រើប្រាស់នូវឯកសារធ្វើដំណើរ ឬអត្តសញ្ញាណនានា ចំពោះបណ្តាគោលបំណងនៃការប្រព្រឹត្តចែងក្នុងមាត្រា ៦ និងមធ្យោបាយនៃការលុបចោលបានប្រើប្រាស់ក្នុងការជួញដូរជនអន្តោប្រវេសន៍ ។

(d)-បង្កើនវិធីវិធីដើម្បីស៊ើបអង្កេតជនដែលបានជួញដូរនូវចំណុចដែលមាន ឬគ្មានអនុសញ្ញានៃការចូលនិងចេញ ។

(e)-ការប្រព្រឹត្តក្នុងលក្ខណៈជាមនុស្សរបស់ជនអន្តោប្រវេសន៍ និងការពារសិទ្ធរបស់ពួកគេមានចែងក្នុងពិធីសារនេះ ។

៣-រដ្ឋជាសមាជិកទាំងអស់តាមរយៈជំនាញការដែលពាក់ព័ន្ធត្រូវពិចារណាផ្តល់ជំនួយបច្ចេកទេសដល់បណ្តារដ្ឋដែលជាញឹកញាប់ជាបណ្តាប្រទេសដើមកំណើត ឬអន្តរចំពោះបុគ្គលដែលជាកម្មវត្ថុនៃការប្រព្រឹត្តបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ។ រដ្ឋជាសមាជិកទាំងអស់ត្រូវយកចិត្តទុកដាក់ដើម្បីផ្តល់ប្រភពចាំបាច់ដូចជាយានយន្ត ប្រព័ន្ធកុំព្យូទ័រ និងអ្នកអានឯកសារ ដើម្បីប្រយុទ្ធប្រឆាំងការប្រព្រឹត្តចែងក្នុងមាត្រា ៦ ។

## មាត្រា ១៥
## បណ្តាវិធានការដទៃទៀត

១-បណ្តារដ្ឋជាសមាជិកត្រូវចាត់វិធានការធានាថាខ្លួនផ្តល់ ឬពង្រឹងកម្មវិធីពត៌មាន ដើម្បីបង្កើនការយល់ដឹងជាសាធារណៈនូវហេតុការណ៍ដែលការប្រព្រឹត្តចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ជាអំពើល្មើសដែលបានប្រព្រឹត្តបទឧក្រិដ្ឋជាញឹកញាប់ដោយក្រុមឧក្រិដ្ឋជនដើម្បីកម្រៃ ហើយដែលខ្លួនលើកឡើងបញ្ហាគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះជនអន្តោ-

ប្រវេសន៍ដែលគេផ្តោតទៅលើ ។

២-អនុលោមតាមមាត្រាទី ៣១ នៃអនុសញ្ញានេះ រដ្ឋជាសមាជិកទាំងអស់ត្រូវសហប្រតិបត្តិការក្នុងវិស័យពតិមានសាធារណៈ សម្រាប់គោលបំណងនៃការទប់ស្កាត់ជនអន្តោប្រវេសន៍ដែលមានសក្តានុភាពពីការទម្លាក់ជនរងគ្រោះទៅក្រុមឧក្រិដ្ឋជន ។

៣-រដ្ឋជាសមាជិកនីមួយៗត្រូវជម្រុញ និងពង្រឹងអោយបានសមស្របការអភិវឌ្ឍន៍កម្មវិធី និងកិច្ចសហប្រតិបត្តិការនៅកម្រិតជាតិ កម្រិតតំបន់ និងកម្រិតអន្តរជាតិ ការចាត់វិធានការ ភាពប្រាកដប្រជាផ្នែកសេដ្ឋកិច្ចសង្គមនៃការធ្វើអន្តោប្រវេសន៍ និងផ្តោតការយកចិត្តទុកដាក់ចំពោះតំបន់ដែលមានការអោក់អន់ចិត្តផ្នែកសេដ្ឋកិច្ចនិងសង្គមដើម្បីប្រយុទ្ធប្រឆាំងបណ្តាបុព្វហេតុនៃសេដ្ឋកិច្ចសង្គមជាឬសគល់នៃការជួញដូរជនអន្តោប្រវេសន៍ដូចជាភាពក្រីក្រ និងភាពអន់ថយ ។

## មាត្រា ១៦
## បណ្តាវិធានការការពារ និងការជំនួយ

១-ក្នុងការអនុវត្តពិធីសារនេះរដ្ឋជាសមាជិទាំងអស់ ស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ ត្រូវចាត់វិធានការសមស្របការដាក់បញ្ចូលបញ្ញត្តិប្រសិនបើចាំបាច់ ដើម្បីថែរក្សាសិទ្ធបុគ្គលដែលជាអ្នកបានប្រព្រឹត្តល្មើសចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ដោយអនុលោមតាមច្បាប់អន្តរជាតិដែលបានអនុវត្តជាពិសេស សិទ្ធិដើម្បីរស់រាន និងសិទ្ធមិនត្រូវបានគេធ្វើទារុណកម្ម ឬអំពើឃោរឃៅដទៃទៀត ការប្រព្រឹត្តដែលមិនមែនជាមនុស្ស ឬការដាក់ទណ្ឌកម្មបញ្ចុះបោន: ។

២-រដ្ឋជាសមាជិកនីមួយៗត្រូវចាត់វិធានការសមស្រប ដើម្បីទទួលយកការការពារសមរម្យក្នុងកានជាជនអន្តោប្រវេសន៍ ប្រឆាំងអំពើហឹង្សាដែលអាចត្រូវបានធ្វើអោយប៉ះពាល់ដល់ពួកគេ ទោះបីដោយបុគ្គល ឬដោយក្រុម ដោយសារតែមូលហេតុនៃការប្រព្រឹត្តល្មើសដែលបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។

៣-រដ្ឋជាសមាជិកនីមួយៗត្រូវទទួលផ្តល់ជំនួយសមរម្យដល់ជនអន្តោប្រវេសន៍ ដែលជីវិត ឬសុវត្ថិភាពរបស់ពួកគេបានជួបគ្រោះថ្នាក់ដោយសារមូលហេតុនៃការប្រព្រឹត្តល្មើស ដែលបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។

៤-ក្នុងការអនុវត្តបញ្ញត្តិនានានៃមាត្រានេះ រដ្ឋជាសមាជិកទាំងអស់ត្រូវចាត់វិធានការចំពោះសេចក្តីត្រូវការពិសេសចំពោះស្ត្រី និងកុមារ ។

៥-ក្នុងករណីនៃការឃុំខ្លួនបុគ្គលម្នាក់ដែលជាអ្នកប្រព្រឹត្តល្មើស បានចែងក្នុងមាត្រា ៦ នៃពីធីសារនេះរដ្ឋជាសមាជិកនីមួយៗត្រូវអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញា វីយែនណា លើទំនាក់ទំនងដែលបានប្រឹក្សាដោយអនុវត្តដាក់បញ្ចូលនូវការរាយការន៍ពីបុគ្គលដែលពាក់ព័ន្ធដោយគ្មានការពន្យារពេល អំពីបទបញ្ញត្តិដែលផ្តោតលើការបញ្ជាក់អះអាងទៅនឹងទំនាក់ទំនងជាមួយមន្ត្រីប្រឹក្សា ។

## មាត្រា ១៧
## កិច្ចព្រមព្រៀង និងការរៀបចំចាត់ចែង

រដ្ឋជាសមាជិកទាំងអស់ត្រូវពិចារណាអំពីការសន្និដ្ឋាននៃកិច្ចព្រមព្រៀងជាឧបតោភាគីឬតាមតំបន់ឬចាត់ចែងប្រតិបត្តិការ ឬការយល់ដឹងមានបំណងចំពោះ :

(a)ការបង្កើតបណ្តាវិធានការដ៏ត្រឹមត្រូវ និងមានប្រសិទ្ធភាពបំផុតដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើល្មើសបានចែងក្នុងមាត្រាទី៦ នៃពិធីសារនេះឬ

(b)ធ្វើអោយប្រសើរឡើងនូវបញ្ញត្តិទាំងឡាយនៃពីធីសារនេះរវាងពួកខ្លួន ។

## មាត្រា ១៨

## ការធ្វើមាតុភូមិនិវត្តន៍របស់ជនអន្តោប្រវេសន៍ដែលត្រូវបានគេជួញដូរ

១-រដ្ឋជាសមាជិកនីមួយៗព្រមព្រៀងដើម្បីសម្រួល និងទទួលយកដោយគ្មានការពន្យារពេលហួសហេតុ ឬមិនសមហេតុផលនូវការធ្វើមាតុភូមិនិវត្តន៍របស់បុគ្គលដែលជាជនល្មើសចែងក្នុងមាត្រា ៦ នៃពិធីសារនេះ និងអ្នកជាជនជាតិខ្លួន ឬអ្នកដែលមានសិទ្ធិតាំងទីលំនៅអចិន្ត្រៃយ៍ក្នុងទឹកដីរបស់ខ្លួននៅពេលនៃការធ្វើមាតុភូមិនិវត្តន៍ ។

២-រដ្ឋជាសមាជិកនីមួយៗត្រូវពិចារណាអំពីលទ្ធភាពនៃការសំរបសំរួល និងការទទួលយកការបញ្ជូន ត្រឡប់នូវបុគ្គលដែលជាជនប្រព្រឹត្តល្មើសចែងក្នុងមាត្រា ៦ នៃពិធីសារនេះហើយដែលមានសិទ្ធិតាំងទីលំនៅអចិន្ត្រៃយ៍ក្នុងទឹកដីរបស់ខ្លួននៅពេលនៃការចូលក្នុងរដ្ឋដែលកំពុងទទួលអនុលោមតាមច្បាប់ស្រុករបស់ខ្លួន ។

៣-តាមសំណើរបស់រដ្ឋជាសមាជិកដែលកំពុងទទួល រដ្ឋជាសមាជិកដែលបានស្នើសុំត្រូវ (ដោយគ្មានការពន្យាពេលហួសហេតុ ឬមិនសមហេតុផល) ផ្ទៀងផ្ទាត់ថាតើបុគ្គលដែលជាជនល្មើសចែងក្នុងមាត្រា ៦ នៃពិធីសារនេះជាជាតិខ្លួន ឬមានសិទ្ធិតាំងលំនៅផ្ទាន់អចិន្ត្រៃយ៍ក្នុងទឹកដីរបស់ខ្លួន ។

៤-ដើម្បីសំរួលដល់ការធ្វើមាតុភូមិនិវត្តន៍នៃជនដែលបានប្រព្រឹត្តល្មើសបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ហើយដោយគ្មានឯកសារត្រឹមត្រូវ រដ្ឋជាសមាជិកដែលជននោះជាជនជាតិ ឬដែលគាត់មានសិទ្ធិតាំងទីលំនៅអចិន្ត្រៃយ៍ត្រូវយល់ព្រមដើម្បីផ្សព្វផ្សាយ (តាមសំណើរបស់ភាគីរដ្ឋដែលកំពុងទទួល) ឯកសារធ្វើដំណើរទាំងនេះ ឬការអនុញ្ញាតដទៃទៀតដែលចាំបាច់ ដើម្បីអាចអោយជននេះធ្វើដំណើរទៅហើយចូលក្នុងទឹកដីរបស់ខ្លួនម្តងទៀត ។

៥-រដ្ឋជាសមាជិកនីមួយៗបានពាក់ព័ន្ធជាមួយការបញ្ជូនត្រឡប់នូវជនល្មើស ដូចបានចែងក្នុងមាត្រា ៦ នៃពិធីសារនេះត្រូវចាត់គ្រប់វិធានការសមរម្យ ដើម្បីធានាមកនូវការបញ្ជូនត្រឡប់ក្នុងលក្ខណៈតាមលំដាប់លំដោយហើយដោយផ្តោតយ៉ាងសម្បើមចំពោះសុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ជននោះ ។

៦-រដ្ឋជាសមាជិកទាំងអស់ត្រូវសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិដែលពាក់ព័ន្ធក្នុងការអនុវត្តន៍មាត្រានេះ ។

៧-មាត្រានេះមិនត្រូវរំលោភទៅលើសិទ្ធិណាមួយ បានផ្តល់ទៅបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តល្មើសចែងក្នុងមាត្រាទី ៦ នៃពិធីសារនេះដោយច្បាប់ក្នុងស្រុករបស់រដ្ឋជាសមាជិកដែលកំពុងទទួល ។

៨-មាត្រានេះនឹងគ្មានធ្វើអោយប៉ះពាល់ដល់រាល់កាតព្វកិច្ចដែលបានដាក់បញ្ចូលនៅក្រោមសន្ធិសញ្ញាណាមួយដទៃទៀតដែលបានអនុវត្តជាទ្វេភាគី ឬពហុភាគី ឬក៏ការអនុវត្តន៍កិច្ចព្រមព្រៀងណា មួយដ៏ទៃទៀតផ្សេងៗទៀតនូវផ្នែកប្រតិបត្តិការ ឬក៏ការចាត់ចែងនោះត្រូវគ្រប់គ្រងទាំងមូល ឬក៏ជាផ្នែក ដូចបានកំពុងទុកនៅក្នុងមាត្រា ៦ នៃពិធីសារនេះ ។

## IV-ឧបសម្ពន្ធបញ្ញត្តិ

### មាត្រា ១៩

### ការជួយសង្គ្រោះ

១-នៅក្នុងពិធីសារនឹងគ្មានអ្វីធ្វើអោយប៉ះពាល់ដល់សិទ្ធិកាតព្វកិច្ច ហើយនឹងការទទួលខុសត្រូវនានានៃបណ្តារដ្ឋនឹងរាល់បុគ្គលក្រោមច្បាប់អន្តរជាតិដោយរាប់បញ្ចូលទាំងច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់សិទ្ធិមនុស្សអន្តរជាតិជាពិសេសដែលអាចអនុវត្តបាននូវអនុសញ្ញាក្នុងឆ្នាំ ១៩៥១ ហើយនឹងឆ្នាំ ១៩៦៧ នៃពិធីសារដែលទាក់ទិនទៅនឹងស្ថានភាពនៃជនភៀសខ្លួនទាំងឡាយ ព្រមទាំងគោលការណ៍ដែលមិនពាក់ព័ន្ធដូចបានចែងនៅក្នុងនោះ ។

២-រាល់បណ្តាវិធានការណ៍ដែលបានកំណត់ទុកនៅក្នុងពិធីសារនេះនឹងត្រូវបានបកស្រាយ ហើយនឹងអនុវត្ត ទៅតាមវិធីដែលមិនមានការប្រកាន់ពូជសាសន៍ ចំពោះជនទាំងឡាយណានៅលើមូលបទដែលជនទាំងនោះបានប្រព្រឹត្ត នូវទោសកម្មដូចបានកំណត់ទុកក្នុងមាត្រា ៦ នៃពិធីសារនេះ ។ ការបកស្រាយហើយនឹងការអនុវត្តន៍នូវរាល់បណ្តា វិធានការណ៍ទាំងនោះនឹងត្រូវបានអនុលោមទៅតាមគោលការណ៍ដែលបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិនៃការមិន ប្រកាន់ពូជសាសន៍ ។

## មាត្រា ២០

## ការដោះស្រាយជម្លោះ

១-បណ្តារដ្ឋដែលជាសមាជិកនឹងត្រូវខិតខំខ្នះខ្នែងដើម្បីដោះស្រាយនូវរាល់ជម្លោះដែលទាក់ទិនការបកស្រាយ ឬក៏ការអនុវត្តន៍នៃពិធីសារនេះតាមរយៈកិច្ចចរចា ។

២-រាល់ជម្លោះណាមួយចាប់ពីពីរឡើងទៅ ឬក៏ច្រើនដែលថែមទៀត រវាងបណ្តារដ្ឋដែលជាសមាជិកដែល ទាក់ទិនទៅនឹងការបកស្រាយ ឬក៏ការអនុវត្តន៍នៃពិធីសារនេះបើមិនអាចដោះស្រាយបានតាមរយៈកិច្ចចរចាទៅតាម ហេតុផលនៃកាលវេលា នៃការស្នើសុំរបស់រដ្ឋមួយក្នុងចំណោមរដ្ឋដែលជាសមាជិកជាច្រើនទៀត ដើម្បីដាក់ជូនពិនិត្យ ទៅគណៈវិនិច្ឆ័យប្រសិនបើរយៈពេល ៦ ខែបន្ទាប់ពីការបរិច្ឆេទនៃការស្នើសុំចំពោះគណៈវិនិច្ឆ័យរាល់បណ្តារដ្ឋដែលជា សមាជិកនៅតែមិនអាចព្រមព្រៀងគ្នានៅលើការចាត់ចែងរបស់គណៈវិនិច្ឆ័យនោះរដ្ឋមួយដែលជាសមាជិកក្នុង ចំណោ មបណ្តារដ្ឋទាំងនោះអាចនឹងបញ្ជូននូវរាល់ជម្លោះនោះជូនទៅដល់តុលាការយុត្តិធម៌អន្តរជាតិទៅតាមសេចក្តីស្នើសុំដោ យអនុលោមទៅតាមលក្ខន្តិកៈរបស់តុលាការ ។

៣-រដ្ឋនីមួយៗដែលជាសមាជិកអាចចុះហត្ថលេខាទៅតាមកាលវេលាសច្ចានុម័ត ការទទួលស្គាល់ ឬក៏អនុម័ត ឬក៏ការយល់ព្រមចំពោះពិធីសារនេះដោយប្រកាសថាច្បាប់នេះមិនទាន់បានធ្វើការពិចារណានិងកែប្រែអោយបានល្អិត ល្អន់ទៅតាមកថាខ័ណ្ឌ ២ នៃមាត្រានេះ ។ បណ្តារដ្ឋដែលជាសមាជិកនឹងមិនអាចកែប្រែទៅតាមកថាខ័ណ្ឌ ២ នៃ មាត្រានេះដោយគោរពទៅតាមរដ្ឋណាមួយដែលជាសមាជិកដែលបានបំរុងទុក ។

៤-រដ្ឋណាមួយដែលជាសមាជិក ដែលបានធ្វើការបំរុងទុកដោយអនុលោមទៅតាមកថាខ័ណ្ឌ ៣ មាត្រានេះ អាចនឹងដកចេញនូវការបំរុងទុកទៅតាមកាលវេលាណាមួយដោយជូនដំណឹងជាមុនដល់អគ្គលេខាធិការអង្គការសហប្រ ជាជាតិ ។

## មាត្រា ២១

## ការចុះហត្ថលេខា សច្ចានុម័ត ការទទួលស្គាល់ ការអនុម័ត ហើយនិងការយល់ព្រម

១-ពិធីសារនេះនឹងត្រូវបានបើកចំហរដល់បណ្តារដ្ឋទាំងអស់សំរាប់ចុះហត្ថលេខាចាប់ពីថ្ងៃទី ១២ ដល់ ខែ ១២ ឆ្នាំ ២០០០ នៅក្នុងរដ្ឋ Palermo ប្រទេសអ៊ីតាលី ហើយបន្ទាប់ពីនោះមកនៅឯទីបញ្ជាការអង្គការសហប្រជាជាតិ នៅក្នុងទីក្រុង ញូយក រហូតដល់ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០០ ។

២-ពិធីសារនេះនឹងត្រូវបើកចំហរផងដែរ សំរាប់ចុះហត្ថលេខាទៅតាមអង្គការសមាហរណកម្មសេដ្ឋកិច្ចនៅ តាមតំបន់ដែលបានផ្តល់អោយយ៉ាងហោចណាស់ក៏មានសមាជិករដ្ឋម្នាក់នៅតាមអង្គការចាត់តាំងដែលបានចុះហត្ថលេ ខានូវពិធីសារនេះដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

៣-ពិធីសារនេះគឺជាប្រធានបទចំពោះការស្នើសច្ចានុម័តការទទួលស្គាល់ ឬក៏អនុម័ត ការធ្វើសច្ចានុម័តនូវ រាល់ឯកសារច្បាប់ ការទទួលស្គាល់ ឬក៏ការអនុម័តនឹងត្រូវបានដាក់ជូនដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ

អង្គការសមាហរណកម្មសេដ្ឋកិច្ចតាមតំបន់ អាចនឹងដាក់នូវការធ្វើសច្ចានុម័តនៃឯកសារច្បាប់របស់ខ្លួន ។ នៅក្នុងការស្នើសច្ចានុម័តនូវឯកសារច្បាប់ ការទទួលស្គាល់ ឬក៏ការអនុម័តទៅតាមអង្គការចាត់តាំងដែលនឹងប្រកាសនូវវិសាល-ភាពនៃសមត្ថភាពរបស់ខ្លួនចំពោះហេតុការណ៍ទាំងឡាយដែលបានគ្រប់គ្រងដោយពិធីសារនេះ ។ ដូចជាការចាត់តាំងនឹងត្រូវបានជំរាបជូនផងដែរដល់អ្នកទទួលបញ្ញើណាមួយដែលពាក់ព័ន្ធទៅនឹងការកែសំរួលនៅក្នុងវិសាលភាពនៃសមត្ថភាពរបស់ខ្លួន ។

៤-ពិធីសារនេះនឹងត្រូវបើកចំហរសំរាប់ការយល់ព្រមទៅតាមរដ្ឋណាមួយ ឬក៏អង្គការសមាហរណកម្មសេដ្ឋកិច្ចតាមតំបន់ដែលយ៉ាងហោចណាស់ក៏ត្រូវរដ្ឋមួយដែលជាសមាជិកចំពោះពិធីសារនេះ ។ ការគ្រប់គ្រងនូវរាល់ឯកសារច្បាប់នឹងត្រូវបានដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការគ្រប់គ្រងរបស់ខ្លួនទៅតាមកាលវេលាអង្គការសមាហរណកម្មសេដ្ឋកិច្ចតាមតំបន់នឹងត្រូវប្រកាសនូវវិសាលភាពនៃសមត្ថភាពរបស់ខ្លួនចំពោះហេតុការណ៍ទាំងឡាយដែលបានចែងនៅក្នុងពិធីសារនេះ ។ ដូចជាការចាត់តាំងនឹងត្រូវបានជំរាបជូនផងដែរដល់អ្នកទទួលបញ្ញើណាមួយដែលពាក់ព័ន្ធទៅនឹងការកែសំរួលនៅក្នុងវិសាលភាពនៃសមត្ថភាពរបស់ខ្លួន ។

## មាត្រា ២២
## ការចូលជាធរមាន

១-ពិធីសារនេះនឹងចូលជាធរមានក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីដាក់អោយធ្វើសច្ចាប័ន នៃការដាក់នូវឯកសារច្បាប់លើកទី ៤០ នៃការធ្វើសច្ចានុម័ត ទទួលស្គាល់ ការអនុម័ត ឬការយល់ព្រមដែលមិនទាន់ចូលជាធរមានមុនពេលការចូលជាធរមាននៃអនុសញ្ញានេះ ។ ចំពោះគោលបំណងនៃកថាខ័ណ្ឌនេះ រាល់ឯកសារច្បាប់ណាមួយដែលបានដាក់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងមិនត្រូវបានរាប់បញ្ចូលបន្ថែមទៀតទេ ចំពោះការដាក់បញ្ចូលទាំងនោះដោយបណ្តារដ្ឋជាសមាជិកទៅតាមអង្គការចាត់តាំង ។

២-ចំពោះបណ្តារដ្ឋនីមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ធ្វើសច្ចាប័ន ធ្វើការទទួលស្គាល់ ធ្វើការអនុម័ត ឬក៏ធ្វើការយល់ព្រមចំពោះពិធីសារនេះ បន្ទាប់ពីដាក់នូវឯកសារច្បាប់លើកទី ៤០ ទៅតាមសកម្មភាពនៃពិធីសារនេះ នឹងចូលជាធរមានរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់តំកល់ទុកដោយរដ្ឋមួយ ឬក៏អង្គការចាត់តាំងដែលពាក់ព័ន្ធទៅនឹងឯកសារច្បាប់ ឬក៏កាលបរិច្ឆេទនៃពិធីសារនេះចូលជាធរមានដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ឬមួយណាក៏បានជាបន្តបន្ទាប់មក ។

## មាត្រា ២៣
## ការធ្វើវិសោធនកម្ម

១-បន្ទាប់ពីផុតកំណត់រយៈពេល ៥ ឆ្នាំ នូវការចូលជាធរមាននៃពិធីសារនេះ រដ្ឋមួយដែលជាសមាជិកចំពោះពិធីសារនេះអាចដាក់ស្នើនូវការកែប្រែ និងសំណុំឯកសារច្បាប់ជូនដល់អគ្គលេខាធិការអង្គការសហប្រជាជាតិដែលភ្លាមៗនេះនឹងទំនាក់ទំនងស្នើសុំធ្វើវិសោធនកម្មទៅបណ្តារដ្ឋដែលជាសមាជិក ព្រមទាំងជូនដល់សន្និបាតនៃភាគីទាំងអស់ចំពោះអនុសញ្ញាក្នុងគោលបំណងធ្វើការពិចារណា និងការសម្រេចចិត្តស្តីពីសំណើរនោះ ។ បណ្តារដ្ឋជាសមាជិកនៃពិធីសារនេះនឹងជួបប្រជុំគ្នានៅឯសន្និសីទនៃបណ្តាភាគីទាំងអស់ និងបង្កើននូវកិច្ចខិតខំប្រឹងប្រែងគ្រប់បែបដើម្បីសម្រេចនូវការព្រមព្រៀងនៃការធ្វើវិសោធនកម្មនីមួយៗ ។ប្រសិនបើរាល់កិច្ចខិតខំប្រឹងប្រែងក្នុងការព្រមព្រៀងមតិគ្នានោះមិនបានសម្រេច ហើយនិងមិនទាន់មានកិច្ចព្រមព្រៀងណាមួយដែលត្រូវបានឈានមកដល់ ការកែប្រែនឹងងាកទៅរកមធ្យោបាយចុងក្រោយបំផុតគឺតម្រូវអោយមានការបោះឆ្នោតក្នុងសម្លេងឆ្នោត ២/៣ នៃបណ្តារដ្ឋជាសមាជិកក្នុងពិធីសារការប្រគល់អោយនិងការបោះឆ្នោតនៅក្នុងការធ្វើសន្និសីទនៃគ្រប់ភាគីទាំងអស់ ។

២-អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ក្នុងបញ្ហាដែលស្ថិតនៅលើសមត្ថកិច្ចរបស់គេ នឹងត្រូវអនុវត្តនូវសិទ្ធិក្នុងការបោះឆ្នោតទៅតាមមាត្រានេះ ដោយចំនួននៃការបោះឆ្នោតស្មើទៅនឹងចំនួនសមាជិកនៃរដ្ឋរបស់គេដែលជា

គូភាគីនៃពិធីសារនេះ ។ រាល់ការចាត់តាំងនឹងមិនត្រូវអនុវត្តទៅតាមសិទ្ធិរបស់គេចំពោះការបោះឆ្នោត ប្រសិនបើរដ្ឋជាសមាជិករបស់គេអនុវត្តផ្ទុយពីសិទ្ធិដែលអនុញ្ញាត ។

៣-ការធ្វើវិសោធនកម្មមួយត្រូវបានអនុម័តយោងទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ជាប្រធានបទដើម្បីធ្វើសច្ចានុម័ត ការយល់ព្រមទទួល ឬក៏អនុម័តដោយបណ្តារដ្ឋជាសមាជិក ។

៤-ការធ្វើវិសោធនកម្មមួយត្រូវបានអនុម័តយោងទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ នឹងត្រូវចូលជាធរមានទៅតាមការគោរពដល់រដ្ឋជាសមាជិកមួយរយៈពេល ៩០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ជូនទៅដល់អគ្គលេខាធិការអង្គការសហប្រជាជាតិនៃការសុំធ្វើសច្ចាប័ននូវឯកសារច្បាប់ ការទទួលស្គាល់ ឬក៏អនុម័តចំពោះការកែប្រែ ។

៥-នៅពេលដែលការស្នើសុំធ្វើវិសោធនកម្មចូលជាធរមាន ដែលច្បាប់នេះកំពុងតែនឹងកែប្រែដោយបណ្តារដ្ឋជាសមាជិកបានបង្ហាញនូវការយល់ព្រមរបស់គេដើម្បីធ្វើការកែប្រែ ។ បណ្តារដ្ឋជាសមាជិកដទៃទៀតនឹងត្រូវតែកែប្រែទៅតាមបទបញ្ញត្តិពិធីសារនេះ ហើយរាល់ការធ្វើវិសោធនកម្មជាលើដំបូងណាមួយដែលពួកគេបានធ្វើសច្ចាប័នបានទទួលស្គាល់ ឬបានអនុម័ត ។

## មាត្រា ២៤

## ការប្រកាសទុកជាមោឃៈ

១-រដ្ឋមួយដែលជាសមាជិកអាចប្រកាសដកខ្លួនចេញពីពិធីសារនេះ ដោយជម្រាបអោយដឹងមុនជាលាយលក្ខណ៍អក្សរជូនដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការប្រកាសទុកជាមោឃៈនឹងត្រូវទទួលយកដោយមានប្រសិទ្ធិភាពរយៈពេល ១ ឆ្នាំ បន្ទាប់កាលបរិច្ឆេទនៃការទទួលនូវការជូនដំណឹងដោយអគ្គលេខា ។

២-អង្គការសមាហរ័ណកម្មសេដ្ឋកិច្ចតំបន់ នឹងត្រូវបញ្ឈប់នូវជាភាគីមួយចំពោះពិធីសារនេះនៅពេលដែលរដ្ឋជាសមាជិករបស់ខ្លួនបានធ្វើការប្រកាសដកខ្លួន ។

## មាត្រា ២៥

## អ្នកចុះបញ្ជី និងភាសា

១-អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបានរៀបចំជាមុន នូវការចុះបញ្ជីនៃពិធីសារនេះ ។

២-ច្បាប់ដើមនៃពិធីសារនេះ នៅក្នុងនោះមានភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង អេស្បាញ និងរុស្ស៊ី ។ អត្ថបទទាំងអស់ពិតជាត្រឹមត្រូវទៅតាមច្បាប់ពិតប្រាកដដែលនឹងបានដាក់ចេញដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ដើម្បីជាសាក្សីក្នុងច្បាប់ទាំងនេះរាល់តំណាងទាំងអស់ត្រូវចុះហត្ថលេខានៅខាងក្រោមទៅតាមការអនុញ្ញាតដ៏ត្រឹមត្រូវចំពោះច្បាប់នោះដោយតំណាងរដ្ឋាភិបាលរៀង១ខ្លួនរបស់គេបានចុះហត្ថលេខាលើពិធីសារនេះ ។